ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**បណ្តឹង/សំណុំរឿង**
លេខ ០៨៨
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**
លេខ ០៣០
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញបទបញ្ជាផ្ទៃក្នុងលេខ ១១៩៨/១២ គ.ជ.ប ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៦១/១៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតឆ្នាំ២០១៦
- បានឃើញពាក្យបណ្តឹង/សំណុំរឿងលេខ ០៨៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់លោក ឌិន រ៉ាវិន ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ១៨ ដល់ ១៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់វាលវង់
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់លោកស្រី ឈន គឹមហៀង ផ្ទេរសិទ្ធិជូនលោក ឌិន រ៉ាវិន ដើម្បីធ្វើជាអ្នកតំណាង
- បានឃើញសេចក្តីសម្រេចលេខ ០០៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ស្តីពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ និងគណៈលេខាធិការសវនាការ

- **ក្រោយពីបានពិនិត្យ និងសិក្សាលើសំណុំរឿង**
- **ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ និងបទបញ្ជា និងនីតិវិធីហើយ**

## ក្រុមប្រឹក្សាជំនុំជម្រះ

- **យល់ឃើញថា** លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់លោកស្រី ឈន គឹមហៀង ផ្ទេរសិទ្ធិជូនលោក ឱន វ៉ាន ធ្វើជាតំណាងក្នុងការចូលរួមសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់។
- **យល់ឃើញថា** ពាក្យបណ្តឹងរបស់លោក ឱន វ៉ារិន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៣ ដល់ ១៣ ១៩ និង ២០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់វាលវង់ ធ្វើឡើងក្នុងកំណត់ច្បាប់ស្របតាមមាត្រា ៦២ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុច ៥.៣.១០.២ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះលើកយកមកពិចារណា និងធ្វើការសម្រេចបាន។
- **យល់ឃើញថា** តាមពាក្យបណ្តឹងចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ និងតាមការឆ្លើយអះអាងបញ្ជាក់របស់លោក ឱន វ៉ារិន ក្នុងកំណត់ហេតុសាកសួរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបញ្ជាក់ថា ខ្លួនសូមប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ១៩ ដល់ ១៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយចេញសេចក្តីសម្រេចមិនបានផ្តល់ភាពយុត្តិធម៌ដល់ខ្លួន។ មូលហេតុដែលខ្លួនប្តឹងលុបឈ្មោះជនបរទេសចំនួន ៥០ នាក់ចេញពីបញ្ជីបោះឆ្នោត ដោយខ្លួនសង្ស័យថា ជាជនជាតិវៀតណាម ដោយសម្អាងលើទម្រង់មុខ និយាយខ្មែរមិនច្បាស់ រស់នៅផ្តុំគ្នាតិច ឬក៏ច្រើន និងគោរពតាមប្រពៃណីតាមទំនៀមទម្លាប់វៀតណាម ហើយផ្ទុយនឹងមាត្រា៤៦ នៃ ច.ប.ត.រ និងមាត្រា១៦ និងមាត្រា១៩ នៃច្បាប់ស្តីពីសញ្ជាតិ តែត្រូវបានក្រុមប្រឹក្សាសង្កាត់វាលវង់ សម្រេចរក្សាទុកក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ដដែល។ ក្នុងករណីនេះ ខ្លួនមានសាក្សីចំនួន ២ នាក់។ ក្នុងរឿងនេះ ខ្លួនសំណូមពរសូមឱ្យ គ.ជ.ប ដោះស្រាយបណ្តឹង និងពិនិត្យឯកសារចុះឈ្មោះបោះឆ្នោតឡើងវិញឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងសូមឱ្យមានវត្តមានឈ្មោះទាំង ៥០ នាក់ខាងលើ ចូលរួមក្នុងពេលសវនាការ។
- **យល់ឃើញថា** តាមការលើកឡើងរបស់លោក ឱន វ៉ារិន ជាតំណាងដើមបណ្តឹង ដោយអះអាងថា អ្នកចុះឈ្មោះបោះឆ្នោតទាំង ៥០ នាក់ សង្ស័យជាជនជាតិវៀតណាម ដោយសម្អាងទៅលើថា ទម្រង់មុខ និយាយខ្មែរមិនច្បាស់ រស់នៅផ្តុំគ្នាតិច ឬក៏ច្រើន និងគោរពតាមប្រពៃណីតាមទំនៀមទម្លាប់វៀតណាម ការលើកឡើងបែបនេះ មិនមានមូលដ្ឋានភស្តុតាងគតិយុត្តដែលអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាជឿបានឡើយ ដោយហេតុថា សញ្ជាតិរបស់បុគ្គលម្នាក់ៗ គេអាចសម្គាល់បានតាមរយៈលិខិតយថាភូតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ច។
- **យល់ឃើញថា** តាមការពិនិត្យ និងស្រាវជ្រាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតសង្កាត់វាលវង់ បញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឃើញថា ក្នុងចំណោមអ្នកទាំង ៥០ នាក់ អ្នកចុះឈ្មោះបោះឆ្នោត ៦ នាក់ បានប្រើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និង ៤៤ នាក់ប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបានមកចុះឈ្មោះបោះឆ្នោតនៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត ស្របតាមមាត្រា៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រការ ៤.៤ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦។
- **យល់ឃើញថា** សេចក្តីសម្រេចលេខ ១៩ ដល់ ១៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់វាលវង់ ដោយសម្រេចរក្សាសម្រេចរក្សាទុកឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតទាំង ៥០ នាក់ ក្នុងបញ្ជីបោះឆ្នោតនៃសង្កាត់វាលវង់ មានលក្ខណៈត្រឹមត្រូវទៅតាមផ្លូវច្បាប់ហើយ។

# សម្រេច

១- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់លោកស្រី ឈន គឹមហៀង ផ្ទេរសិទ្ធិជូនលោក ខិន វ៉ារិន ធ្វើជាតំណាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ របស់លោក ខិន វ៉ារិន ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

៣- តម្កល់សេចក្តីសម្រេចលេខ ១៤ ដល់ ១៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាប្រជុំសម្រេចសង្កាត់វាលវង់ ទុកជាបានការពេញទាំងមូល។

៤- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយបើកផ្លូវប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមកំណត់ច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៧

**ជ.ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប**

**ប្រធាន**

ស៊ិក ប៊ុនហុក